# ស័ង្ខសិល្បជ័យ

ភាគទី២

ក្បួនដង្ហែក៏បានមកដល់រាជវាំង ពួកក្មេងចាប់ផ្តើមប្រគំទទួលស្វាគមន៍នាងទាំងប្រាំពីរ ហើយស្តេចក៏ត្រាស់បញ្ជាឲ្យរៀបបណ្ណាការ និងរៀបអភិសេកឥឡូវនេះ។ ព្រះអង្គសេនាកុត្តរាជបានត្រាស់បញ្ជាឲ្យសាងប្រាសាទយ៉ាងល្អប្រណិតសម្រាប់មហេសីទាំងប្រាំពីរអង្គ។ កន្លងពេលក្រោយមក មហេសីទាំងប្រាំមួយក៏ទ្រង់គភ៌ហើយប្រសូតបានបុត្រម្នាក់មួយសុទ្ធតែប្រុស...។ រាជបុត្រទីមួយឈ្មោះ ស្រីសុន្ទរា ទីពីរព្រះនាមសីលព័ត្ត ទីបីព្រះនាមស្រីមន្ទារថ្វាត់ ទីបួនព្រះនាមស្រីសុរនាថសោភ័ណ ទីប្រាំព្រះនាម ស្រីសុជាតិហេមវន្ត ទីប្រាំមួយព្រះនាមស្រីខន្ធកុមារ...។ ព្រះបិតាថ្នាក់ថ្នមបុត្រទាំងប្រាំមួយអង្គមិនឲ្យមានហ្មងឡើយ។ លុះចំណេរក្រោយមក ស្នំឯកកេសរបុប្ផាក៏មានផ្ទៃពោះកន្លងទៅជាងមួយខែ ទើបនាងនាងពៅបទុមាទ្រង់គភ៌។ ពេលដែលបទុមាទ្រង់គភ៌ អស់ប្រាណមានរស្មីយ៉ាងត្រកាលនាំឲ្យព្រះអង្គសេនាកុត្តរាជពេញព្រះទ័យថ្នាក់ថ្នមមិនឲ្យហ្មងឡើយ...។ លុះកេសរបុប្ផាមានផ្ទៃគ្រប់ខែហើយ ក៏ប្រសូតមកកើតជារាជសីហ៍មានឫទ្ធិខ្លាំងក្រៃ អស់អ្នកផងយល់ថាជារឿងចម្លែកពេកណាស់។ រីឯអគ្គមហេសីបទុមា ទ្រង់ប្រសូតបុត្រមកជារាជបុត្រល្អភ្លឺត្រកាលមានកាន់ធ្នូសិល្ប៍ជ័យ និងមានខ្យងស័ង្ខប្រសូតមកជាមួយគ្នាផងដែរ។ អស់គីលៀងអ្នករាំងទាំងអស់យល់ថាជាហេតុអស្ចារ្យណាស់ ទើបនាំគ្នាទៅទូលដល់ព្រះមហាក្សត្រ។ ព្រះអង្គសេនាកុត្តរាជទ្រង់ជ្រាបហើយមានព្រះទ័យរីករាយជាពន់ពេក ទ្រង់យាងទៅទតមើល រួចទ្រង់យល់ថាបុត្រដែលមានបារមីខ្លាំងក្លាពេកក្រៃ ទើបទ្រង់ត្រាស់បញ្ជាគីលៀង យាយអករ៍ ចាស់ទុំថែរក្សាឲ្យបានល្អ...។ កាលនោះដែរ ពួកនាងជាបងៗបានមកមើលឃើញហើយ ស្ញប់ស្ញែងបារមីរាជកុមារណាស់។ លុះវិលមកដល់ប្រាសាទវិញ ក៏ប្រជុំគ្នាថា: "កូននាងពៅបទុមាមានឫទ្ធិបារមីណាស់ ធំឡើងនឹងគ្មាននរណាប្រៀបស្មើបានទេ ហើយកូនយើងជាបងនឹងពុំអាចប្រៀបផ្ទឹមបានឡើយ ដូច្នេះហើយគួររកវិធី

អត្ថបទដោយ៖ មាស សុភាព

កម្ចាត់វាពីតូចឲ្យហើយទៅ"។ កាលនោះនាងម្នាក់ឈ្មោះថា ស្រីសុន្ទរាមានប្រាជ្ញាជាងគេ បានហៅអស់ហោរាមកជួបជុំ ហើយថា:

ហៃហោរទាំងបួន យើងទុកស្មើខ្លួន ស្មើឯកអង្គា
ពាក្យណាសុខុម ហោរកុំចរចារ ឲ្យលេចព្ធជា
ត្រចៀកទៀតបាន។
បើមហាក្សត្រា ព្រះបាទសេនា កុត្តរាជប្រធាន
ត្រាស់ឲ្យហៅមក ហោរទៅគ្រប់ប្រាណ ដល់ព្រះរាជឋាន
ឲ្យគួរជតា។
កូនតូចឯក្រោយ កុំហោរទាយដោយ នូវពាក្យសត្យា
ហោរទូលអសត្យ បំភ្លាត់វិញថា កូនកើតពុំជា
ឧត្បាតកើតមាន។

រីឯសរកាន់នៅដៃនោះនឹងត្រូវព្រះអង្គពុំខាន។ ឯស័ង្ខវិញនោះច្បាស់ជាកើតជាទឹកលិចអស់អាណាប្រជានុរាស្ត្រស្លាប់គ្មានសល់...។ ចំណែកឯរាជសីហ៍សត្វវិញនោះ ស្រុកទេសនេះនឹងស្ងាត់ជាព្រៃព្រឹក្សាវិនាសគ្មានសល់...។ គឺទុកកូននោះនៅមិនបានទេ ទាល់តែបំបរបង់ចោលទើបស្រុកទេសបានសេចក្ដីសុខចម្រើនរុងរឿង។ ចូរហោរទូលព្រះអង្គថា កូនយើងគ្រប់គ្នានេះមានបុណ្យបានស្នងរាជសម្បត្តិ បានសុខពេកហោង។ បើហោរធ្វើបានសម្រេចនោះ ពួកយើងនឹងឲ្យរង្វាន់ម្នាក់ប្រាំពីរពាន់តម្លឹង...។

លុះកំណត់រួចស្រេចហើយ ហោរទាំងអស់ក៏ក្រាបលាត្រលប់ទៅផ្ទះវិញ។ ដោយសេចក្ដីលោភ ហោរមិនបានគិតថានឹងមានរឿងអកុសលកើតឡើងនៅថ្ងៃក្រោយឡើយ។ រំលងបានប្រាំពីរថ្ងៃ ព្រះអង្គសេនាកុត្តរាជ ក៏ត្រាស់ឲ្យហៅហោរាទាំងបួន មកទាយជោគជតារាសីរាជបុត្រពៅ។ ដោយបានកំណត់រួចស្រេចនោះ ហោរទាំងបួនក៏ធ្វើជាយំគក់ទ្រូងរៀបរាប់។ ទតឃើញដូច្នោះ ព្រះអង្គសេនាកុត្តរាជទ្រង់ត្រាស់សួរ: "តើហេតុអ្វីបានជាហោរយំដូច្នេះចូរនិយាយមកចុះ"។ ហោរទាំងបួនក៏បានរៀបរាប់តាមពាក្យដែលបានកំណត់រួចជាស្រេចថា: "នឹងមានគ្រោះកាចចង្រៃពេកណាស់ មិនដូចជាកូនក្សត្រីបងទាំងប្រាំមួយទេ មានជតារាសីល្អឥតសង្ស័យទេ"។ ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ស្ដេចសេនាកុត្តរាជកើត

ក្ដីក្រោធមហិមា ត្រាស់ថា: " អញគិតស្មានថាគាប់ អញរាប់អានវា បើកូនពុំជាតើទុកធ្វើអ្វី កូនកាចអប្រិយបែបនេះ យកទៅប្រហារជីវិតចោលទៅ..."។ ឮដូច្នោះព្រាហ្មណ៍ទាំងអស់ក៏ទូលថា: "សម្លាប់មិនបានទេព្រះអង្គ នឹងកើតកាចកំណាចមហិមា ព្រោះថាឈាមដែលធ្លាក់ដល់ដីនឹងឆាបឆេះ ហើយខ្មោចរក្សាទីនោះ នឹងផុសឡើងឲ្យកើតទុក្ខទោសខ្លាំងណាស់ ដូច្នេះសូមព្រះអង្គបំបរបង់ទៅ ហើយទូលបង្គំនឹងធ្វើពិធីបូជាយញ្ញ នោះនឹងបានសេចក្ដីសុខរុងរឿងហើយ"។ លុះហោរទាំងបួនចេញទៅ អង្គសេនាកុត្តរាជទ្រង់ព្រះចិន្តាថា:

អាសូរបំណាច់ កើតជាកូនស្ដេច ទោះកាចទោះជា<br>
ចិញ្ចឹមទុកទៅ ឲ្យនៅនេះណា មើលសិនរលា<br>
រលាំងព្រោះថ្វី។

ហើយម្យ៉ាងបទុមាក៏គួរមហាសន្ដោសពុំគួរនឹងបំបរបង់ឡើយ។ កាលនោះបុត្រីបទុមាបានឮទំនាយហោរដូច្នោះ ក៏ឡើងទៅក្រាបបង្គំទូលថា:

បពិត្រហោរគួរ ហើយហោរក្រាបទូល ពាក្យពុំសត្យា<br>
ហោរទូលបំភ្លាត់ អសត្យវាចា កុំព្រះរាជា<br>
ជឿហោរចង្រៃ។

បំណាច់កើតពីក្សត្រ ហើយម្យ៉ាងទើបតែបានប្រាំពីរថ្ងៃទៀត សូមព្រះអង្គមេត្តាផង បើបុត្រធំបេះស្រដីដឹងខ្លះនោះខ្ញុំម្ចាស់មិនថាទេ។ អង្គក្សត្រសេនាកុត្តរាជ ទ្រង់ព្រះសណ្ដាប់ហើយក៏មានបន្ទូលថា:

មាសអើយកុំគិត អំពល់អាណិត អនាថសោកា<br>
ចូរចុះទៅហោង ស្ងួនគ្រងរក្សា បុត្រយើងពុំងា<br>
ដូចដែលប្រក្រតី។

ទោះកូនកាចជាយ៉ាងណា ក៏ចិញ្ចឹមតាមបុណ្យបារមីទៅចុះ...។ ព្រះនាងបទុមាឮក្សត្រមានបន្ទូលដូច្នោះ ក៏បានធូរស្រាលក្នុងចិត្ត ហើយក្រាបបង្គំលាត្រលប់ទៅវិញ...។ និយាយពីក្សត្រីប្រាំមួយអង្គ កាលបានដឹងរឿងហើយ ក៏ស្រុះស្រួលមូលមតិគ្នាឡើងទៅគាល់ស្ដេចហើយនាងជាបងឈ្មោះឯកមាល័យក៏:

អត្ថបទដោយ៖ មាស សុភាព

ទូលថាសូមទាន ឥឡូវនេះមាន ហេតុកលក្រក្រៃ
ហោរទូលព្រះអង្គ ដោយត្រង់វិស័យ ចៅស័ង្ខសិល្បជ័យ
កើតមកពុំជា។

មានទាំងរាជសីហ៍សោតក៏មិនល្អ កេសរបុប្ផាទាំងបទុមាប្អូនខ្ញុំម្ចាស់ សុទ្ធតែបង្កើតកូនមកពុំជា គួរអ្វីខ្ញុំម្ចាស់ឲ្យបំបរបង់ក្មួយឯង តែនេះជាពាក្យហោរាដែលសុទ្ធតែធុតពេកក្រៃ ហេតុនេះសូមព្រះអង្គព្រះចិន្តាឲ្យបានហ្មត់ចត់ព្រះអង្គ...។ ព្រះអង្គសេនាកុត្តរាជទ្រង់ព្រះសណ្ដាប់ហើយ មានមន្ទូលថា: "សូមនាងកុំគិតថ្វី ព្រោះថាក្មួយនាងនោះមិនមានវិស័យដូចជានាងគិតទេ យើងចិញ្ចឹមរក្សាសិន បើពុំជាសឹមបំបរបង់ក៏បាន"។ ប៉ុន្តែបើតាមពាក្យហោរាទស្សន៍ទាយនោះ គឺគ្រោះចង្រៃមិនអាចគេចបានឡើយ ហើយបើចាំដល់ពេលកើតហេតុចាំបំបរបង់នោះ គឺហួសពេលហើយព្រះអង្គ។

ព្រះអង្គសេនាកុត្តរាជ ទ្រង់សណ្ដាប់រួច ប្រឹងមិនមានបន្ទូលអ្វីសោះ ទ្រង់ព្រះចិន្តាសោយសោកាអាណិតដល់បុត្រ និងមហេសីណាស់។ ដោយគិតថាធ្វើអ្វីមិនបាន ទើបក្សត្រីទាំងប្រាំមួយក្រាបបង្គំលាត្រលប់ទៅវិញ ហើយរកមធ្យោបាយដើម្បីឲ្យស្ដេចបំបរបង់ឲ្យបាន។

**(សូមរង់តាមដានរឿង ស័ង្ខសិល្បជ័យ ភាគទី៥ នៅសប្ដាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព